ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ក្រមសីលធម៌មន្ត្រីមានសមត្ថកិច្ច
## ក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោង
## ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៤ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៩ និង មាត្រា ១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៥ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._ គោលបំណង**

អនុក្រឹត្យនេះកំណត់អំពីគោលការណ៍គ្រឹះនៃក្រមសីលធមិមន្ត្រីមានសមត្ថកិច្ចក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាពីគ្រប់ប្រភពហិរញ្ញប្បទាន ដើម្បី÷

- ពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការសិក្សា ការអនុវត្ត និងការគ្រប់គ្រងគម្រោង ព្រមទាំងការវាយតម្លៃគម្រោងថវិកាប៉ាន់ស្មានសម្រាប់ចំណាយលើការអនុវត្តគម្រោង
- បង្កើនជំនឿទុកចិត្តពីសាធារណជន ស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍លើការសិក្សា និងការអនុវត្តគម្រោង
- ទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានគម្រោងដែលមិនត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីជាធរមាន និងរាល់សកម្មភាពកេងចំណេញដោយប្រើប្រាស់ព័ត៌មានគម្រោង។

**មាត្រា ២._ វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីមានសមត្ថកិច្ចទាំងអស់ដែលមានការពាក់ព័ន្ធនឹងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទានទាំងអស់ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងទាំងនេះ។

**មាត្រា ៣._ និយមន័យ**

និយមន័យនៃវាក្យសព្ទនៃអនុក្រឹត្យនេះត្រូវបានកំណត់នៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី ២
## គោលការណ៍គ្រឹះនៃក្រមសីលធមិ

**មាត្រា ៤._ គោលការណ៍គ្រឹះនៃក្រមសីលធមិ**

មន្ត្រីមានសមត្ថកិច្ចត្រូវប្រតិបត្តិមុខងាររបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍គ្រឹះនៃក្រមសីលធមិដូចខាងក្រោម÷

១. អនុលោមភាព÷ ត្រូវប្រតិបត្តិការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងទាំងនេះ ឱ្យស្របតាមច្បាប់ គោលនយោបាយ ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២. សុចរិតភាព÷ ត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងភាពត្រឹមត្រូវ ដោយត្រូវជៀសវាងសកម្មភាពទាំងឡាយណាដែលនាំឱ្យប៉ះពាល់ដល់តម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីមានសមត្ថកិច្ច ជាអាទិ៍ មិនត្រូវប្រព្រឹត្តអំពើពុករលួយ ឬអំពើកេងបន្លំ ឬទទួលអំណោយ លាភការ ឬអត្ថប្រយោជន៍ផ្សេងៗ ដោយផ្ទាល់ ឬដោយប្រយោលពីបុគ្គលណាមួយនៅក្នុងកិច្ចដំណើរការសិក្សា រៀបចំ អនុវត្ត និងគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងទាំងនេះ។

៣. ភាពមិនលម្អៀង÷ ត្រូវធានានូវយុត្តិធម៌ សមធម៌ ឬភាពមិនលម្អៀងក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងក្នុងការអង្កេត និងវាយតម្លៃផលប៉ះពាល់ដោយសារគម្រោងទាំងនេះ។

៤. ការរក្សាការសម្ងាត់វិជ្ជាជីវៈ÷ ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ ដោយមិនត្រូវផ្សព្វផ្សាយតាមមធ្យោបាយណាមួយក៏ដោយ ឬធ្វើឱ្យបែកធ្លាយនូវព័ត៌មានគម្រោង និងព័ត៌មានរសើបរបស់គម្រោង នៅមុនពេលដែលគម្រោងត្រូវបានអនុម័តជាផ្លូវការ និងអាចផ្សព្វផ្សាយបានជាសាធារណៈស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែក្នុងករណីដែលត្រូវបានកំណត់ផ្សេងពីនេះដោយគោលនយោបាយ ឬកិច្ចព្រមព្រៀងគតិយុត្តផ្សេងជាមួយដៃគូអភិវឌ្ឍន៍ ឬដែលជាការតម្រូវរបស់តុលាការមានសមត្ថកិច្ច។

៥. ទំនាស់ផលប្រយោជន៍÷ ត្រូវអនុវត្តការងារ និងធ្វើការសម្រេចទាំងឡាយនៅក្នុងការបំពេញមុខងារ និងការទទួលខុសត្រូវជាផ្លូវការរបស់ខ្លួន ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ដោយត្រូវជៀសវាងជាដាច់ខាតនូវទំនាក់ទំនង ឬធ្វើសកម្មភាពណាមួយដែលបម្រើឱ្យផលប្រយោជន៍ឯកជន នៅក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនេះ។

៦. សមត្ថភាពវិជ្ជាជីវៈ÷ ត្រូវប្រតិបត្តិមុខងាររបស់ខ្លួនអស់ពីសមត្ថភាព ប្រកបដោយវិជ្ជាជីវៈ ទេពកោសល្យភាពឈ្លាសវៃ ប្រសិទ្ធភាព និងគណនេយ្យភាព និងត្រូវប្រកាន់ខ្ជាប់នូវចរិយាមារយាទ ឥរិយាបទ និងប្រើប្រាស់ពាក្យសម្តីសមរម្យប្រកបដោយសុជីវធម៌ សីលធម៌ និងមិនមានការរើសអើងក្នុងការបំពេញការងារ។

៧. ការចូលរួម÷ ត្រូវចូលរួមសហការតាមកម្រិតការងាររបស់ខ្លួន ដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ នៅគ្រប់ដំណាក់កាលទាំងអស់នៃការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

## ជំពូកទី ៣
## វិធានប្រតិបត្តិគោលការណ៍គ្រឹះនៃក្រមសីលធម៌

### មាត្រា ៥._ វិធានប្រតិបត្តិគោលការណ៍គ្រឹះនៅតាមដំណាក់កាលនានានៃវដ្តរបស់គម្រោង

#### ក. ដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង

អនុលោមតាមគោលការណ៍គ្រឹះខាងលើ អ្នកអនុវត្តគម្រោង រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងមន្ត្រីមានសមត្ថកិច្ចទាំងអស់ត្រូវប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវវិធានដូចខាងក្រោម÷

១. អ្នកអនុវត្តគម្រោង និងមន្ត្រីមានសមត្ថកិច្ច មិនត្រូវធ្វើការផ្សព្វផ្សាយជាដាច់ខាតនូវរាល់ព័ត៌មានគម្រោង ឬផែនការរបស់គម្រោងដែលមិនទាន់បានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគសាធារណៈ ០៣ ឆ្នាំរំកិលរបស់រាជរដ្ឋាភិបាល និងដែលមិនទាន់ត្រូវបានអនុម័តជាផ្លូវការដោយរាជរដ្ឋាភិបាលនៅឡើយ។

២. ក្នុងករណីដែលគោលនយោបាយរបស់ដៃគូអភិវឌ្ឍន៍តម្រូវឱ្យមានការផ្សព្វផ្សាយព័ត៌មានគម្រោងនៅក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង មន្ត្រីមានសមត្ថកិច្ចអាចផ្សព្វផ្សាយបាននូវរាល់ព័ត៌មានដែលមិនមានលក្ខណៈជាព័ត៌មានរសើបរបស់គម្រោង។

៣. ចំពោះគម្រោងដែលមានតម្រូវការធ្វើលទ្ធកម្មដីដើម្បីបម្រើឱ្យការសាងសង់នៅលើទីតាំងថ្មី ក្រៅពីទីតាំង ឬគន្លងដែលមានស្រាប់ ជាអាទិ៍ គម្រោងផ្លូវ ផ្លូវវាង ព្រលានយន្តហោះ ធារាសាស្ត្រ ទីលានចាក់សំរាម អាងប្រព្រឹត្តិកម្ម អគាររដ្ឋបាល ឬអគារសាធារណៈ ឬគម្រោងថ្មីដែលមានលក្ខណៈប្រហាក់ប្រហែលផ្សេងទៀត អ្នកអនុវត្តគម្រោងត្រូវសិក្សាគំនូសប្លង់បច្ចេកទេសគម្រោងឱ្យមានជម្រើសយ៉ាងតិចពីរ ដោយមានការសិក្សាវាយតម្លៃ ថ្លឹងថ្លែងឱ្យបានគ្រប់ជ្រុងជ្រោយ រួមទាំងការគិតគូរបញ្ចៀសនូវការប្រើប្រាស់ដីលើសតម្រូវការរបស់គម្រោង និងការកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ច ឱ្យបានជាអតិបរមាដើម្បីសន្សំសំចៃថវិកាជាតិ។

៤. អ្នកអនុវត្តគម្រោង និងមន្ត្រីរបស់អ្នកអនុវត្តគម្រោង មិនត្រូវសិក្សាគំនូសប្លង់បច្ចេកទេសគម្រោងសំដៅធ្វើយ៉ាងណាឱ្យតម្រុយ ឬតម្រាយរបស់គម្រោងរត់កាត់តាមទីតាំងដី ឬត្រូវសាងសង់ឡើងនៅលើទីតាំងដីរបស់មន្ត្រីមានសមត្ថកិច្ច សហព័ទ្ធ ឬសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច ឬរបស់បុគ្គលណាមួយ ដើម្បីទទួលបានផលប្រយោជន៍ពីបុគ្គលនោះ ឬដើម្បីផ្តល់ផលប្រយោជន៍ដល់បុគ្គលនោះទេ។

៥. អ្នកអនុវត្តគម្រោងត្រូវសហការជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការសិក្សា និងវាយតម្លៃផលប៉ះពាល់ដោយសារគម្រោង ស្របតាមគោលការណ៍និងនីតិវិធីជាធរមាន សំដៅកាត់បន្ថយទំហំនៃផលប៉ះពាល់ និងកំណត់ឱ្យបានច្បាស់ពីទំហំថវិកាដែលត្រូវចំណាយលើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោង។

៦. ស្ថាប័នជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធត្រូវទប់ស្កាត់ចំពោះសកម្មភាពទន្ទ្រានកាន់កាប់ដី ឬទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត និងមិនត្រូវចូលរួម ឬបង្កលក្ខណៈងាយស្រួលដល់សកម្មភាពទាំងនេះនៅតាមទីតាំងគម្រោង ដើម្បីទាមទារសំណងពីរដ្ឋជាដាច់ខាត។

៧. មន្ត្រីមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់មិនត្រូវប្រើសិទ្ធិអំណាច ឬមុខតំណែងណាមួយរបស់ខ្លួន ដើម្បីទិញ-លក់ ដោះដូរ ឬធ្វើលទ្ធកម្មដីនៅតាមទីតាំងគម្រោង ទាំងមុន និងក្រោយពេលដែលការសិក្សាសមិទ្ធិលទ្ធភាពត្រូវបានបញ្ចប់ដើម្បីផលប្រយោជន៍ឯកជននៅក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោងនោះទេ។ ការហាមឃាត់នេះត្រូវអនុវត្តផងដែរចំពោះសហព័ទ្ធ និងសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច រាប់ទាំងញាតិលោហិត និងញាតិពន្ធតាមការកំណត់របស់ច្បាប់។

៨. ក្រោយពេលដែលថ្ងៃឱសានវាទនៃសិទ្ធិទទួលបានសំណងរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវបានកំណត់ច្បាស់លាស់ស្របតាមគោលនយោបាយ និងនីតិវិធីជាធរមាន មន្ត្រីមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវសហការគ្នាផ្សព្វផ្សាយថ្ងៃឱសានវាទនេះជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជ្រាបឱ្យបានទូលំទូលាយ ហើយត្រូវចូលរួមទប់ស្កាត់នូវរាល់ការទិញ-លក់ ដោះដូរ ឬធ្វើលទ្ធកម្មដី ការកែលម្អដី ឬទ្រព្យសម្បត្តិផ្សេងទៀត ការសាងសង់ថ្មី ឬសកម្មភាពផ្សេងទៀតទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅកេងចំណេញផ្ទាល់ខ្លួនពីគម្រោងនៅក្នុងតំបន់នៃទីតាំងគម្រោងដែលនឹងធ្វើឱ្យប៉ះពាល់ ឬជះឥទ្ធិពលជាអវិជ្ជមានដល់តម្លៃដីនៅក្នុងតំបន់នេះ ក៏ដូចជាបង្កឧបសគ្គនានាដល់ការអនុវត្តគម្រោង។

**ខ. ដំណាក់កាលអនុវត្តគម្រោង**

អនុលោមតាមគោលការណ៍គ្រឹះខាងលើ អ្នកអនុវត្តគម្រោង រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងមន្ត្រីមានសមត្ថកិច្ចទាំងអស់ត្រូវប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវវិធានដូចខាងក្រោម÷

១. ក្នុងករណីដែលថ្ងៃឱសានវាទនៃសិទ្ធិទទួលបានសំណងត្រូវបានកំណត់នៅក្នុងដំណាក់កាលនៃការអនុវត្តគម្រោង មន្ត្រីមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ត្រូវសហការគ្នាផ្សព្វផ្សាយថ្ងៃឱសានវាទនេះជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជ្រាបឱ្យបានទូលំទូលាយ ហើយត្រូវចូលរួមទប់ស្កាត់នូវរាល់ការទិញ-លក់ ដោះដូរ ឬធ្វើលទ្ធកម្មដី ការកែលម្អដី ឬទ្រព្យសម្បត្តិផ្សេងទៀត ការសាងសង់ថ្មី ការទន្ទ្រានកាន់កាប់ដី ឬសកម្មភាពផ្សេងទៀតទាំងឡាយណាដែលធ្វើឡើងក្នុងគោលដៅកេងចំណេញផ្ទាល់ខ្លួនពីគម្រោងនៅក្នុងតំបន់នៃទីតាំងគម្រោងដែលនឹងធ្វើឱ្យប៉ះពាល់ ឬជះឥទ្ធិពលជាអវិជ្ជមានដល់តម្លៃដីនៅក្នុងតំបន់នេះ ក៏ដូចជាបង្កឧបសគ្គនានាដល់ការអនុវត្តគម្រោង។

២. មន្ត្រីរបស់អ្នកអនុវត្តគម្រោងត្រូវសិក្សាគំនូសប្លង់បច្ចេកទេសគម្រោងឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ រួមទាំងការគិតគូរបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ច ឱ្យបានជាអតិបរមាមុននឹងដាក់ជូនប្រធានស្ថាប័នអនុម័តជាផ្លូវការ។ ការអនុវត្តការងារដោះស្រាយផលប៉ះពាល់មិនអាចចាប់ផ្ដើមដំណើរការបានទេ ប្រសិនបើគំនូសប្លង់បច្ចេកទេសគម្រោងមិនទាន់ត្រូវបានអនុម័តជាផ្លូវការ លើកលែងចំពោះគម្រោងដែលការងារដោះស្រាយផលប៉ះពាល់អាចដំណើរការបានដោយមិនចាំបាច់រង់ចាំឱ្យមានគំនូសប្លង់បច្ចេកទេស ក្រោយពេលរបៀងនៃផលប៉ះពាល់របស់គម្រោងត្រូវបានអនុម័តជាផ្លូវការ។

៣. មន្ត្រីរបស់អ្នកអនុវត្តគម្រោងមិនត្រូវកែសម្រួលគំនូសប្លង់បច្ចេកទេសគម្រោងសំដៅធ្វើយ៉ាងណាឱ្យគម្រោងរត់កាត់តាមទីតាំងដី ឬត្រូវសាងសង់ឡើងនៅលើទីតាំងដីរបស់មន្ត្រីមានសមត្ថកិច្ច សហព័ទ្ធ ឬសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច ឬរបស់បុគ្គលណាមួយ ដើម្បីទទួលបានផលប្រយោជន៍ពីបុគ្គលនោះ ឬដើម្បីផ្តល់ផលប្រយោជន៍ដល់បុគ្គលនោះទេ។

៤. អ្នកអនុវត្តគម្រោងសហការជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវគិតគូររៀបចំយន្តការបង្កកដីដែលត្រូវធ្វើលទ្ធកម្មសម្រាប់គម្រោងឱ្យបានទាន់ពេលវេលា ក្រោយពេលមានការប្រកាសគម្រោងស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ ការកំណត់សំណងថ្លៃដីនឹងត្រូវគិតត្រឹមកាលបរិច្ឆេទនៃការប្រកាសគម្រោងដែលនឹងត្រូវធ្វើឡើងនៅក្រោយពេលដែលគម្រោងត្រូវបានអនុម័តរួច ស្របតាមនីតិវិធីជាធរមាន។

៥. មន្ត្រីមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់មិនត្រូវទិញ-លក់ ដោះដូរ ឬធ្វើលទ្ធកម្មដីដើម្បីផលប្រយោជន៍ឯកជននៅតាមទីតាំងជាក់លាក់របស់គម្រោងនៅគ្រប់ដំណាក់កាលនៃការអនុវត្តការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងជាដាច់ខាត ដរាបណាការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងមិនទាន់ត្រូវបានបញ្ចប់ជាស្ថាពរ។ ការហាមឃាត់នេះត្រូវអនុវត្តផងដែរចំពោះសហព័ទ្ធ និងសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច រាប់ទាំងញាតិលោហិត និងញាតិពន្ធតាមការកំណត់របស់ច្បាប់។

៦. មន្ត្រីទទួលបន្ទុកការងារដោះស្រាយផលប៉ះពាល់ត្រូវធ្វើការអង្កេតវាស់វែងលម្អិត និងវាយតម្លៃផលប៉ះពាល់ដោយសារគម្រោងឱ្យបានត្រឹមត្រូវ ច្បាស់លាស់ មានតម្លាភាព និងមិនលម្អៀង។

៧. មន្ត្រីទទួលបន្ទុកការងារដោះស្រាយផលប៉ះពាល់ត្រូវគណនាចំនួនប្រាក់សំណងចំពោះដី និងទ្រព្យសម្បត្តិផ្សេងៗដែលត្រូវរងផលប៉ះពាល់ដោយសារគម្រោងឱ្យបានត្រឹមត្រូវ ច្បាស់លាស់ មានតម្លាភាព យុត្តិធម៌ និងមិនលម្អៀង ស្របតាមច្បាប់ គោលការណ៍ និងគោលនយោបាយសំណងជាធរមាន។

៨. មន្ត្រីទទួលបន្ទុកការងារដោះស្រាយផលប៉ះពាល់ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធត្រូវពន្យល់ផ្សព្វផ្សាយអំពីមូលដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសម្របសម្រួលដោយសន្តិវិធីជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ ដើម្បីឱ្យពួកគាត់ធ្វើការរុះរើដោយស្ម័គ្រចិត្តនូវសំណង់ស្រាលៗដែលអាចរំកិលបានដែលបានសាងសង់ឡើងនៅលើដីរដ្ឋដោយខុសច្បាប់ ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ថារដ្ឋនឹងមិនធ្វើការដោះស្រាយជាប្រាក់សំណងគោលនយោបាយថ្លៃសំណង់ទាំងនេះជូនពួកគាត់នោះទេ។

៩. មន្ត្រីមានសមត្ថកិច្ចមិនត្រូវជ្រៀតជ្រែក ឬអន្តរាគមក្នុងរូបភាពណាមួយក៏ដោយ ដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោល ដល់ដំណើរការអង្កេតវាស់វែងលម្អិត និងវាយតម្លៃផលប៉ះពាល់ដោយសារគម្រោង និងដល់ការសិក្សានិងការកំណត់អត្រានិងចំនួនប្រាក់សំណង និង/ឬប្រាក់ឧបត្ថម្ភគោលនយោបាយចំពោះដីនិងទ្រព្យសម្បត្តិផ្សេងៗដែលត្រូវរងផលប៉ះពាល់ដោយសារគម្រោងនោះទេ។

**គ. ដំណាក់កាលក្រោយការអនុវត្តគម្រោង**

អនុលោមតាមគោលការណ៍គ្រឹះខាងលើ អ្នកអនុវត្តគម្រោង រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងមន្ត្រីមានសមត្ថកិច្ចទាំងអស់ ត្រូវប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវវិធានដូចខាងក្រោម÷

១. រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធត្រូវសម្របសម្រួល និងចាត់វិធានការម៉ឺងម៉ាត់ ដើម្បីធ្វើការរុះរើសំណង់ និងទ្រព្យសម្បត្តិផ្សេងៗដែលបានដោះស្រាយជាប្រាក់សំណង ឬប្រាក់ឧបត្ថម្ភគោលនយោបាយរួចរាល់។

២. អ្នកអនុវត្តគម្រោងត្រូវធានាថាការងារឈូសឆាយទីតាំងគម្រោងត្រូវធ្វើឡើងស្របតាមរបៀងនៃផលប៉ះពាល់របស់គម្រោងដែលត្រូវបានដោះស្រាយផលប៉ះពាល់រួច និងត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតនានាដែលបណ្ដាលមកពីការបំពានកាតព្វកិច្ចនេះ។

៣. រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវពង្រឹងការគ្រប់គ្រង និងទប់ស្កាត់រាល់ការទន្ទ្រានកាន់កាប់សារជាថ្មី និងការសង់សំណង់ផ្សេងៗបន្ថែម លៀនលយ ឬរំលោភចូលដីចំណីផ្លូវ ឬរបៀងនៃផលប៉ះពាល់ ឬទ្រព្យសម្បត្តិរដ្ឋផ្សេងទៀតដែលរដ្ឋបានដោះស្រាយរួច។ រដ្ឋនឹងមិនផ្ដល់សំណងម្ដងទៀតចំពោះរាល់ការទន្ទ្រានកាន់កាប់ឡើងវិញលើដីរដ្ឋ ឬទ្រព្យសម្បត្តិផ្សេងទៀតដែលបានដោះស្រាយផលប៉ះពាល់រួចនោះទេ នៅពេលដែលរដ្ឋមានតម្រូវការក្នុងការអភិវឌ្ឍបន្ថែមទៀត។

៤. ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវរៀបចំចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋឱ្យបានត្រឹមត្រូវតាមនីតិវិធីជាធរមាន នូវរាល់ដីឯកជនដែលបានធ្វើលទ្ធកម្មរួចសម្រាប់បម្រើឱ្យគម្រោងនិងការអភិវឌ្ឍបន្ថែមនាពេលអនាគត។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងដីរដ្ឋ ត្រូវពង្រឹងការគ្រប់គ្រងដីឯកជនដែលរដ្ឋបានធ្វើលទ្ធកម្មរួចនេះ និងទប់ស្កាត់ឱ្យបានទាន់ពេលនូវរាល់ការទន្ទ្រានកាន់កាប់ដីនេះ។

៥. រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវទប់ស្កាត់ចំពោះសកម្មភាពទន្ទ្រានកាន់កាប់ដី ឬទ្រព្យសម្បត្តិផ្សេងទៀតដែលបានដោះស្រាយផលប៉ះពាល់រួច និងមិនត្រូវចូលរួម ឬបង្កលក្ខណៈងាយស្រួលដល់សកម្មភាពទាំងនេះជាដាច់ខាត ព្រោះការណ៍នេះនឹងបង្កជាឧបសគ្គដល់ការអភិវឌ្ឍនាពេលអនាគត។

**មាត្រា ៦._ វិធានប្រតិបត្តិគោលការណ៍គ្រឹះនៅគ្រប់ដំណាក់កាលនៃវដ្ដរបស់គម្រោង**

**ក. ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង**

អនុលោមតាមគោលការណ៍គ្រឹះខាងលើ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅតាមទីតាំងគម្រោង ដោយប្រតិបត្តិនូវវិធានដូចខាងក្រោម÷

១. ត្រូវបំពេញតួនាទីជាអ្នកបម្រើផលប្រយោជន៍សាធារណៈនិងប្រជាពលរដ្ឋ ដោយត្រូវប្រកាន់ខ្ជាប់នូវអាកប្បកិរិយានិងឥរិយាបថសមរម្យ ថ្លៃថ្នូរ ទន់ភ្លន់ សុភាពរាបសា ម៉ឺងម៉ាត់ មិនរើសអើង និងប្រើប្រាស់ពាក្យសម្ដីសមរម្យ ប្រកបដោយសុជីវធម៌ និងសីលធម៌។

២.ផ្សព្វផ្សាយនិងពន្យល់ប្រជាពលរដ្ឋឱ្យបានច្បាស់លាស់ និងបើកទូលាយឱ្យមានការចូលរួមមតិយោបល់ពីប្រជាពលរដ្ឋនៅតាមទីតាំងគម្រោង ជាពិសេសមតិយោបល់និងសំណូមពរនានារបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ និងក្រុមជនក្រីក្រនិងជនងាយរងគ្រោះពាក់ព័ន្ធនឹងគម្រោង។ រាល់មតិយោបល់ទាំងនេះត្រូវកត់ត្រាទុកឱ្យបានត្រឹមត្រូវ និងត្រូវយកមកពិចារណាក្នុងការធ្វើសេចក្ដីសម្រេច។

**ខ. ការហាមឃាត់ចំពោះការផ្សព្វផ្សាយ និងការប្រើប្រាស់ព័ត៌មានគម្រោង**

អនុលោមតាមគោលការណ៍គ្រឹះខាងលើ មន្ត្រីមានសមត្ថកិច្ចត្រូវអនុវត្តតាមវិធានដូចខាងក្រោម÷

១. មិនត្រូវផ្សព្វផ្សាយតាមមធ្យោបាយណាមួយក៏ដោយ ឬធ្វើឱ្យបែកធ្លាយនូវព័ត៌មានទូទៅ ឬព័ត៌មានបច្ចេកទេសរបស់គម្រោង នៅមុនពេលដែលគម្រោងមួយត្រូវបានអនុម័តជាផ្លូវការ និងអាចផ្សព្វផ្សាយបានជាសាធារណៈស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែក្នុងករណីដែលត្រូវបានកំណត់ក្នុងចំណុច ក. ២ នៃមាត្រា ៥ នៃអនុក្រឹត្យនេះ។

២. មិនត្រូវប្រើប្រាស់ព័ត៌មានទូទៅរបស់គម្រោង ឬព័ត៌មានបច្ចេកទេសរបស់គម្រោងដែលបានទទួលក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន ឬរបស់អង្គភាពខ្លួន ដើម្បីធ្វើសកម្មភាព ឬប្រកបមុខរបរណាមួយពាក់ព័ន្ធនឹងដីធ្លីនៅទីតាំងគម្រោង សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ទោះដោយផ្ទាល់ ឬដោយប្រយោល ឬសម្រាប់ផលប្រយោជន៍របស់គតិយជនណាមួយជាដាច់ខាត។

**គ. ទំនាស់ផលប្រយោជន៍**

អនុលោមតាមគោលការណ៍គ្រឹះខាងលើ មន្ត្រីមានសមត្ថកិច្ចត្រូវជៀសវាងជាដាច់ខាតនូវទំនាក់ទំនង ឬធ្វើសកម្មភាពណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ជាមួយមុខងាររបស់ខ្លួន។

ត្រូវបានចាត់ទុកថាជាទំនាស់ផលប្រយោជន៍ក្នុងករណីជាអាទិ៍ដូចខាងក្រោម÷

១. ការប្រើប្រាស់ ឬការឆ្លៀតយកមុខតំណែង ឬឥទ្ធិពលរបស់ខ្លួន ឬរបស់អ្នកដទៃ ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ទោះដោយផ្ទាល់ ឬដោយប្រយោល ពីការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនេះ។

២. ការសិក្សាគំនូសប្លង់បច្ចេកទេសគម្រោងសំដៅធ្វើយ៉ាងណាឱ្យតម្រុយ ឬតម្រាយរបស់គម្រោងរត់កាត់តាមទីតាំងដី ឬត្រូវសាងសង់ឡើងនៅលើទីតាំងដីរបស់មន្ត្រីមានសមត្ថកិច្ច សហព័ទ្ធ ឬសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច ឬរបស់បុគ្គលណាមួយ ដើម្បីទទួលបានផលប្រយោជន៍ពីបុគ្គលនោះ ឬដើម្បីផ្ដល់ផលប្រយោជន៍ដល់បុគ្គលនោះ។

៣. ការទិញ-លក់ ដោះដូរ ឬធ្វើលទ្ធកម្មដីនៅតាមទីតាំងគម្រោង ទាំងក្នុងដំណាក់កាលសិក្សា និងដំណាក់កាលអនុវត្តគម្រោង នៅមុនពេលដែលការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងត្រូវបាន

បញ្ចប់រួចរាល់ជាស្ថាពរ។ ការទិញ- លក់ ដោះដូរ ឬធ្វើលទ្ធកម្មដីនៅតាមទីតាំងគម្រោងនៅក្នុងដំណាក់កាលទាំងនេះដោយសហព័ទ្ធ ឬសាច់ញាតិរបស់មន្ត្រីមានសមត្ថកិច្ច រាប់ទាំងញាតិលោហិត និងញាតិពន្ធតាមការកំណត់ដោយច្បាប់ ត្រូវចាត់ទុកជាទំនាស់ផលប្រយោជន៍ផងដែរ។

៤. ការជ្រៀតជ្រែក ឬអន្តរាគមណាមួយដែលជះឥទ្ធិពលជាអវិជ្ជមានដោយផ្ទាល់ ឬដោយប្រយោលដល់ការវាយតម្លៃផលប៉ះពាល់ដោយសារគម្រោង និងដល់ការសិក្សានិងការកំណត់អត្រាសំណងនិងចំនួនប្រាក់សំណង និង/ឬប្រាក់ឧបត្ថម្ភគោលនយោបាយ ចំពោះដីនិងទ្រព្យសម្បត្តិផ្សេងៗដែលត្រូវរងផលប៉ះពាល់ដោយសារគម្រោង។

## ជំពូកទី ៤
## ទណ្ឌកម្ម និងយន្តការដាក់ទណ្ឌកម្ម

### មាត្រា ៧._ ទណ្ឌកម្ម

មន្ត្រីមានសមត្ថកិច្ចដែលបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌នេះត្រូវទទួលទណ្ឌកម្មវិន័យ និងទណ្ឌកម្មដទៃទៀតដូចបានកំណត់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា ៨._ យន្តការដាក់ទណ្ឌកម្ម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលលើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍អាចជូនដំណឹងអំពីករណីមិនគោរពតាមក្រមសីលធម៌នេះទៅប្រធានស្ថាប័នពាក់ព័ន្ធដើម្បីមានវិធានការបន្ត ឬគោរពរាយការណ៍ដោយផ្ទាល់ជូនប្រមុខរាជរដ្ឋាភិបាលក្នុងករណីចាំបាច់។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

### មាត្រា ៩._ ការផ្សព្វផ្សាយក្រមសីលធម៌

ប្រធានស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទទាំងអស់ ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តត្រូវអប់រំ និងផ្សព្វផ្សាយក្រមសីលធម៌នេះឱ្យបានទូលំទូលាយដល់មន្ត្រីពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ការយល់ដឹង សំដៅបង្ការ និងទប់ស្កាត់ឱ្យបានទាន់ពេលវេលានូវរាល់សកម្មភាពទាំងឡាយណាដែលផ្ទុយនឹងក្រមសីលធម៌នេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

### មាត្រា ១០._ និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១១._ ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១១
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ

## សទ្ទានុក្រម

**គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសាធារណៈ:** ដូចបានកំណត់ក្នុងមាត្រា ៥ នៃច្បាប់ស្តីពីអស្សាមិករណ៍ មានជាអាទិ៍÷

ក- ការសាងសង់ ឬពង្រីកផ្លូវអាកាសយានដ្ឋាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និងឧបករណ៍។

ខ- ការសាងសង់ ឬពង្រីកស្ថានីយថាមពលរចនាសម្ព័ន្ធ ឧបករណ៍ និងខ្សែសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី។

គ- ការសាងសង់ ឬពង្រីកអគារ និងឧបករណ៍សម្រាប់ប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា។

ឃ- ការសាងសង់ ឬពង្រីកផ្លូវ ផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និងទីលានសាធារណៈ។

ង- ការសាងសង់ ឬពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និងកន្លែងបម្រើសេវាសាធារណៈផ្សេងទៀត។

ច- ការសាងសង់ ឬពង្រីកអគារសម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និងកីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ។

ឆ- ការសាងសង់ ឬពង្រីកកន្លែងចម្រាញ់ និងកន្លែងប្រព្រឹត្តិកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និងបរិស្ថាន។

ជ- ការសាងសង់ ឬពង្រីកអគារ និងឧបករណ៍សម្រាប់ស្រាវជ្រាវ និងសម្រាប់ការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិផ្សេងទៀត។

ឈ- ការសាងសង់ ឬពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្រប្តូមប្រេង និងបណ្តាញដទៃទៀត។

ញ- ការសាងសង់ ឬពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិមានរញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និងគ្រោះបាក់ដីជាដើម និងការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ។

ដ- ការសាងសង់ ឬពង្រីកអគារសម្រាប់ការការពារ និងការគាំពារប្រជាជន។

ឋ- ការសាងសង់ ឬពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន។

ឌ- ការសាងសង់ ពង្រីក ឬការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬការងារសន្តិសុខ។

ឍ- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភណ្ឌ វប្បធម៌បុរាណវិទ្យា ឬការពារបរិស្ថាន។

ណ- ការអនុវត្តតាមតម្រូវការរបស់ជាតិតាមការកំណត់របស់រាជរដ្ឋាភិបាល។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីរបស់អ្នកអនុវត្តគម្រោង មន្ត្រីទទួលបន្ទុកការងារដោះស្រាយផលប៉ះពាល់ មន្ត្រី ឬបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីគ្រប់ស្ថាប័នសាធារណៈទាំងអស់ដែលមានការពាក់ព័ន្ធទោះដោយផ្ទាល់ ឬដោយប្រយោល នឹងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនេះ។

**មន្ត្រីរបស់អ្នកអនុវត្តគម្រោង** សំដៅដល់មន្ត្រីរាជការ និងបុគ្គលិកមិនមែនជាមន្ត្រីរាជការនៅគ្រប់អង្គភាពទាំងអស់របស់អ្នកអនុវត្តគម្រោង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទោះមាន ឬមិនមានតួនាទី និងភារកិច្ចផ្ទាល់លើការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

**អ្នកអនុវត្តគម្រោង** សំដៅដល់រដ្ឋ (ជាអាទិ៍ដូចជា ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាដើម) សហគ្រាសនិងគ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន ដែលមានតួនាទីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

**មន្ត្រីទទួលបន្ទុកការងារដោះស្រាយផលប៉ះពាល់** សំដៅដល់មន្ត្រីរាជការ និងបុគ្គលិកមិនមែនជាមន្ត្រីរាជការរបស់គ្រប់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងវិស័យឯកជន ដែលមានតួនាទី និងភារកិច្ចដោយផ្ទាល់ ឬដោយប្រយោល ក្នុងការសិក្សា ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

**មន្ត្រី ឬបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់មន្ត្រី ឬបុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រី ឬបុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រី ឬបុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំង ឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រី ឬបុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកអណ្ដែត និងទីប្រឹក្សាបច្ចេកទេសដែលបានជ្រើសរើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មន្ត្រីគ្រប់ស្ថាប័នសាធារណៈ** សំដៅដល់បុគ្គលិកជាមន្ត្រីរាជការ និងបុគ្គលិកមិនមែនជាមន្ត្រីរាជការរបស់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរ និងអង្គភាពផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

**បុគ្គលិកមិនមែនជាមន្ត្រីរាជការ** សំដៅដល់មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្ដែត ទីប្រឹក្សាបច្ចេកទេសសិក្សាគំនូសប្លង់គម្រោង ភ្នាក់ងារអង្កេតវាស់វែងលម្អិត ភ្នាក់ងារឯករាជ្យសិក្សាអត្រាថ្លៃជំនួស ភ្នាក់ងារត្រួតពិនិត្យពីខាងក្រៅ និងទីប្រឹក្សាបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត។

**គំនូសប្លង់បច្ចេកទេស** សំដៅដល់គំនូសប្លង់ដែលបង្ហាញពីទីតាំងជាក់លាក់របស់គម្រោងមានជាអាទិ៍ គំនូសប្លង់បច្ចេកទេសលម្អិត, គំនូសប្លង់ទីតាំង, គំនូសប្លង់មេ, គំនូសប្លង់បង្ហាញទីតាំងដីចំណីផ្លូវ ឬរបៀងនៃផលប៉ះពាល់, គំនូសប្លង់បង្ហាញពីអ័ក្សផ្លូវឬអ័ក្សប្រឡាយ, ប្លង់រូប ឬគ្រោងប្លង់លម្អិត ជាដើម។

**របៀងនៃផលប៉ះពាល់** សំដៅដល់ទីតាំងដែលរងផលប៉ះពាល់ដោយសារការងារសាងសង់របស់គម្រោង និង/ ឬទីតាំងដែលទទួលបានការអនុម័តជាផ្លូវការពីក្រសួង- ស្ថាប័នអនុវត្តគម្រោង ថាចាំបាច់សម្រាប់បម្រើឱ្យការងារសាងសង់របស់គម្រោង។

**ថ្ងៃឱសានវាទ** សំដៅដល់កាលបរិច្ឆេទដែលកំណត់សិទ្ធិទទួលបានសំណងគោលនយោបាយ និងប្រាក់ឧបត្ថម្ភនានារបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង។

ថ្ងៃឱសានវាទគឺជាកាលបរិច្ឆេទនៃការបញ្ចប់ដំណើរការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់នៅក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង ឬកាលបរិច្ឆេទនៃការបញ្ចប់នូវការពិគ្រោះយោបល់ដែលបានធ្វើឡើងមុនពេលធ្វើការអង្កេតវាស់វែងលម្អិត ក្នុងករណីគំនូសប្លង់បច្ចេកទេសត្រូវបានរៀបចំរួចរាល់ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង។

ចំពោះគម្រោងដែលមិនមានតម្រូវការក្នុងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់នៅក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង ថ្ងៃឱសានវាទគឺជា (១) កាលបរិច្ឆេទនៃការអនុម័តជាផ្លូវការលើការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោង ឬលើការសិក្សាគំនូសប្លង់បច្ចេកទេសរបស់គម្រោង ឬ (២) កាលបរិច្ឆេទនៃការអនុម័តជាផ្លូវការលើទំហំរបៀងនៃផលប៉ះពាល់របស់គម្រោងចំពោះគម្រោងដែលការងារដោះស្រាយផលប៉ះពាល់អាចដំណើរការបានដោយមិនចាំបាច់រង់ចាំឱ្យមានគំនូសប្លង់បច្ចេកទេសជាមុន ឬ (៣) កាលបរិច្ឆេទនៃលិខិតគតិយុត្តដែលសម្រេចអំពីការបង្កកដីដែលជាតម្រូវការរបស់គម្រោង។

ប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារគម្រោងត្រឹមថ្ងៃឱសានវាទមានសិទ្ធិទទួលបានសំណងគោលនយោបាយ ឬប្រាក់ឧបត្ថម្ភនានា។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការកែលម្អដី ឬទ្រព្យសម្បត្តិផ្សេងទៀតក្រោយថ្ងៃឱសានវាទ នោះនឹងគ្មានសំណងគោលនយោបាយ ឬប្រាក់ឧបត្ថម្ភចំពោះការកែលម្អនេះទេ។ លើសពីនេះទៀត ចំពោះបុគ្គលដែលចូលមកប្រើប្រាស់ ឬកាន់កាប់តំបន់នៃគម្រោងក្រោយថ្ងៃឱសានវាទ នឹងគ្មានសិទ្ធិទទួលសំណងគោលនយោបាយ ឬប្រាក់ឧបត្ថម្ភអ្វីទាំងអស់ ទោះបីបុគ្គលនេះមានស្ថានភាពសេដ្ឋកិច្ច ឬសង្គមបែបណាក៏ដោយ។

**ព័ត៌មានសើប** សំដៅដល់ព័ត៌មានអំពីទីតាំងជាក់លាក់របស់គម្រោង ឬគំនូសប្លង់បច្ចេកទេសរបស់គម្រោង។